បទវិចារណកថា

## **សារៈសំខាន់នៃការជឿទុកចិត្ត**

ការជឿទុកចិត្តពីសាធារណជនគឺជាកត្តាសំខាន់មួយនៃស្ថិរភាព ដូចដែលឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស លោក ហ្សេត រ៉ាអាដ អាល់-ហ៊ូសសេន (Zeid Ra'ad Al-Hussein) ពន្យល់៖ ‶ប្រទេសមួយដែលមានស្ថិរភាព គឺជាប្រទេសដែលប្រជាជនមានការជឿទុកចិត្តលើរដ្ឋាភិបាល និងមានការជឿទុកចិត្តគ្នាទៅវិញទៅមក″។ ការជឿទុកចិត្តពីសាធារណជន មិនមែនកើតមាន ដោយឯកឯង ឬដោយចៃដន្យឡើយ។ វាកើតចេញពីភាពបើកចំហ និងកិច្ចសន្ទនាដោយត្រង់ៗមិនលាក់លៀម ទោះជាការសន្ទនានោះឡើងកំដៅក្តី។ ផ្នែក ឬចំណែកសំខាន់ៗរួមគ្នា បង្កើតបានជាសកម្មភាពជាក់ស្តែង ដែលបង្ហាញថា ការជឿទុកចិត្ត គឺគ្រប់គ្រាន់សមល្មមនឹងទទួលបាន។ ការណ៍ដែលអាជ្ញាធរបានអនុញ្ញាតឲ្យមានការរៀបចំពិធីអបអរសាទរទិវាពលកម្មអន្តរជាតិ ដោយសន្តិវិធីដោយគ្មានការរិតត្បិត កាលពីពីរសប្តាហ៍កន្លងមកនេះ ពិតជារាប់បានថាជាករណីមួយ ក្រោយពីមានការប្រកាសប្រមានផ្ទុយពីនេះ។ ការដោះលែងឲ្យនៅក្រៅឃុំកាលពីពេលថ្មីៗនេះ នូវសកម្មជនបឹងកក់ រាប់ថាជាករណីមួយផ្សេងទៀត ដែលនេះគឺជាមធ្យោបាលវិជ្ជមានមួយ ក្នុងការទទួលអបអរថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ ក៏ដូចជា ការកែប្រែភាពអយុត្តិធម៌មួយដែលមិនសមាមាត្រា។

ក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈចុងក្រោយមុនពេលចប់អាណត្តិរបស់លោក នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកសាស្ត្រាចារ្យ សុរិយា ស៊ូប៉ែឌី បានបន្ទរទស្សនៈរបស់ឧត្តមស្នងការ ដែលសង្កត់ធ្ងន់ថា៖ ‶របៀបវារៈកំណែទម្រង់ មិនមែនជាកិច្ចការរបស់គណបក្សកាន់អំណាច និងគណបក្សប្រឆាំង ដែលត្រូវធ្វើ ឬត្រូវពិភាក្សាគ្នាតែឯងឡើយ។ ផ្ទុយទៅវិញ វាគឺជារបៀបវារៈថ្នាក់ជាតិមួយ ដែលតាមរយៈនេះ មនុស្សគ្រប់ស្រទាប់ជាន់ថ្នាក់ គួរតែមានឱកាសចូលរួម និងមានភាពជាម្ចាស់...]។ [ថា] ច្បាប់សំខាន់ៗមួយចំនួន ត្រូវបានអនុម័តកាលពីពេលថ្មីៗនេះ ដោយគ្មានការចូលរួមជាសាធារណៈប្រកបដោយអត្ថន័យនោះ... គឺបានបញ្ជូនសារអវិជ្ជមានមួយដល់សាធារណជនថា វិធីចាស់នៃការគ្រប់គ្រងប្រទេសមិនបានផ្លាស់ប្តូរឡើយ ហើយវាគឺជារឿងអយុត្តិធម៌មួយ សម្រាប់អ្នកទាំងឡាយដែលមានបំណងពិតប្រាកដក្នុងការធ្វើកំណែទម្រង់ ដែលខ្ញុំជឿថា មាននៅក្នុងគណបក្សធំៗទាំងពីរ...″ អនុសាសន៍ចុងក្រោយរបស់លោកគឺ ‶ដើម្បីបើកកិច្ចដំណើរការដ៏មានសារសំខាន់ នៃការធ្វើច្បាប់ និងជំនះបាននូវមតិរិះគន់″ – មិនមែនជាការច្រានចោលច្បាប់ទាំងនោះឡើយ ផ្ទុយទៅវិញ វាគឺជាកម្លាំងបន្ថែមលើអំណះអំណាងរបស់លោក អ្នក និងឆន្ទៈមួយដែលស្តែងឲ្យឃើញ ពីការធ្វើដំណើរលើមាគ៌ាដ៏ល្អបំផុត ឈានទៅដោះស្រាយបញ្ហាផ្សេងៗ ដោយមិនគិតថា អ្នកណាគឺជាអ្នកស្នើច្បាប់ទាំងនោះឡើយ។″

ផ្ទុយទៅវិញ ច្បាប់ដ៏សំខាន់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ត្រូវបានគេរាយការណ៍ថា ទើបបានដាក់ជូនគណៈរដ្ឋមន្ត្រី ហើយដែលនឹងត្រូវអនុម័តនៅក្នុងខែនេះ។ នៅថ្ងៃទី៤ ខែឧសភា មានអង្គការសង្គមស៊ីវិល ជាង ៣០០ ដែលធ្វើការក្នុងវិស័យផ្សេងៗគ្នាជាច្រើន បានមកជួបជុំគ្នា ដើម្បីស្នើឲ្យរដ្ឋាភិបាល ‶បញ្ឈប់ ហើយត្រូវពិគ្រោះ″ ជាមួយពួកគេ។ ការអំពាវនាវនោះមានមិនត្រឹមតែពីក្រុមអង្គការតូចៗដែលហ៊ាននិយាយស្តីជាងគេប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត ដែលធ្វើការផ្នែកអភិវឌ្ឍន៍ផងដែរ ដែលប្រទេសជាតិពឹងអាស្រ័យយ៉ាងខ្លាំងលើអង្គការទាំងនោះ។ ការឆ្លើយតបដ៏មាន

ប្រយោជន៍នោះ អាចជាការពន្យារវិធីសាស្ត្រនៃភាពបើកចំហដល់ការអនុម័តច្បាប់ ដូចដែលក្រសួងមួយចំនួនបាននិងកំពុងធ្វើដូច្នោះដែរ តាមរយៈការបញ្ចូលជាផ្លូវការនៅក្នុងដំណើរការធ្វើច្បាប់នូវវិធានជាក់លាក់ ដែលតម្រូវឲ្យមានការចូលរួមប្រកបដោយតម្លាភាព ពីសាធារណជន។ វាគឺជាកាតព្វកិច្ចសិទ្ធិមនុស្សមួយ ក៏ដូចជាវិធីមួយដែលមានប្រយោជន៍ក្នុងការកសាងការជឿទុកចិត្ត និងការធានាបាននូវស្ថិរភាពយូរអង្វែង។

បរិយាកាសមិនប្រាកដប្រជា នាពេលបច្ចុប្បន្ននេះ ហើយការមិនជឿទុកចិត្ត កើតចេញពីការដែលថាក្រៅពីរដ្ឋាភិបាល មិនមាននរណាម្នាក់ដឹងអំពីខ្លឹមសារនៃសំណៅចុងក្រោយបំផុតនៃសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ឡើយ។ ករណីដូចគ្នានេះ មានផងដែរ ចំពោះសេចក្តីព្រាងច្បាប់ស្តីពីសហជីព។ ដំណើរការនេះ កើតមានក្រោយពីការអនុម័តច្បាប់គ្រឹះទាំងបី ស្តីពីប្រព័ន្ធតុលាការដែលទទួលរងការរិះគន់ពីមនុស្សជាច្រើន ពីភាពស្រពិចស្រពិល និងដែលនាំឲ្យមានការគិតថា ការងារធានាឲ្យមានឯករាជ្យភាពរបស់តុលាការ នៅមិនទាន់ពេញលេញនៅឡើយ។

ប្រសិនបើមានការសង្ស័យណាមួយថាតើការធានាឲ្យមានការចូលរួមពីសាធារណជនគឺជាកាតព្វកិច្ចមួយ ឬយ៉ាងណានោះ វាជាជំនួយមួយដល់យើងដែលត្រូវរំលឹកឡើងវិញនូវ មាត្រា ២១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សដែលចែងថា "មនុស្សគ្រប់រូបមានសិទ្ធិចូលរួមក្នុងការដឹកនាំកិច្ចការសារធារណៈនៃប្រទេសរបស់ខ្លួន។" សេចក្តីចែងដូចនេះត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាពិសេសនៅក្នុងមាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ នៅក្នុងសេចក្តីពន្យល់ទូទៅ លេខ២៥ របស់ខ្លួន គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ជាស្ថាប័នជំនាញមួយដែលឃ្លាំមើលការអនុវត្តនូវកតិកាសញ្ញានេះ ពន្យល់ថា ប្រជាពលរដ្ឋ "ចូលរួមនៅក្នុងកិច្ចការសាធារណៈដោយប្រើប្រាស់ឥទ្ធិពលតាមរយៈកិច្ចជជែកពិភាក្សាដេញដោលជាសាធារណៈ និងកិច្ចពិភាក្សាជាមួយតំណាងរបស់ខ្លួន ឬតាមរយៈសមត្ថភាពរបស់ខ្លួនដែលរៀបចំធ្វើឡើងដោយខ្លួនផ្ទាល់។" ពាក់ព័ន្ធនឹងប្រទេសកម្ពុជា គណៈកម្មាធិការនេះទើបតែបានផ្តល់អនុសាសន៍ កាលពីពីរខែមុននេះ ថា ខ្លួន "ធានាឲ្យមានតម្លាភាពនៅក្នុងដំណើរការនីតិកម្ម យ៉ាងជាក់លាក់។"

យោងតាមបទដ្ឋានសិទ្ធិមនុស្ស និងបទពិសោធន៍ កិច្ចដំណើរការគឺមានសារៈសំខាន់ដូចលទ្ធផលចុងក្រោយដែរ។ ក្រសួងបរិស្ថានបានយល់បញ្ហានេះហើយក៏បានអញ្ជើញអង្គការជាតិ និងអន្តរជាតិឲ្យចូលរួមនៅក្នុងកិច្ចដំណើរការ ដែលមានការចូលរួមច្រើនបំផុតនៃការផ្តល់សេចក្តីពន្យល់លម្អិតលើសេចក្តីព្រាងច្បាប់ដែលយើងបានឃើញនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ករណីនេះធ្វើឡើងគឺក្នុងគោលបំណងដើម្បីតម្រូវឲ្យរាល់ គម្រោងអភិវឌ្ឍន៍ទាំងអស់ ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងឲ្យប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ចូលរួមនៅក្នុងគម្រោងទាំងនោះ។ ក្រសួងព័ត៌មានក៏បានយល់អំពីចំណុចនេះផងដែរ ហើយបាន សន្យាចាប់ផ្តើមធ្វើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានតាមរយៈ "ក្រុមការងារបច្ចេកទេស" ដែល មានការចូលរួម ដោយរួមបញ្ចូលទាំងអង្គការសង្គមស៊ីវិលជាតិនានា ក៏ដូចជាទីភ្នាក់ងារអង្គការសហប្រជាជាតិ ដែលមានជំនាញឯកទេសលើបញ្ហានេះផងដែរ។

អង្គការក្រៅរដ្ឋាភិបាលនានាបាន និងបន្តដើរតួនាទីយ៉ាងសំខាន់មួយក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីបង្កើតសេវាសង្គមប្រកបដោយគុណភាព អង្គការក្រៅរដ្ឋាភិបាលទាំងនេះគឺជាតួអង្គដ៏សំខាន់ក្នុងការជួយគាំទ្រក្រសួងមួយចំនួនធំដើម្បីអនុវត្តឲ្យសម្រេចគោលដៅអភិវឌ្ឍន៍ គាំទ្រដល់កំណើនសេដ្ឋកិច្ចដ៏

ខ្លាំងក្លាក្នុងប្រទេសនេះ។ ការធ្វើដូចនេះដើម្បីឲ្យបានដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត នៅតាមភូមិតូចៗបំផុត ហើយនាំមកនូវការគាំទ្រ ដែលរដ្ឋាភិបាលបានទទួលស្គាល់ថា នាពេលបច្ចុប្បន្ន ភូមិទាំងនោះមិនទាន់មានការរៀបចំត្រឹមត្រូវ និងផ្តល់ជាធនធានឲ្យបានគ្រប់គ្រាន់នៅឡើយទេ។ ភាពជាដៃគូដ៏ល្អកើតមានទៅបាននៅពេលដែលមានកិច្ចសន្ទនាដោយបើកចំហ និងការផ្លាស់ប្តូរមតិយោបល់គ្នាដោយត្រង់ៗមិនលាក់លាម និងការកសាងឲ្យមានការជឿទុកចិត្ត។

ក្នុងស្មារតីនេះហើយដែលការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មូលនិធិអង្គការសហប្រជាជាតិ ដើម្បីកុមារ (UNICEF) មូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) អង្គការសហប្រជាជាតិដើម្បីស្ត្រី (UN Women) បានរួមគ្នាលើកទឹកចិត្តថា សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) គួរតែត្រូវបានរំលែក (ផ្សព្វផ្សាយ) ឲ្យបានឆាប់ៗតាមដែលអាចធ្វើបាន ហើយថា កិច្ចពិគ្រោះយោបល់ពិតប្រាកដលើសេចក្តីព្រាងច្បាប់នេះ គួរតែធ្វើឡើង ហើយត្រូវធ្វើការពិចារណាឲ្យបានពិតប្រាកដលើអនុសាសន៍នានាមុនពេលពិនិត្យបញ្ចប់ច្បាប់នេះ។ យើងត្រៀមខ្លួនរួចជាស្រេចដើម្បីជួយគាំទ្ររដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលធ្វើការរៀបចំកិច្ចពិគ្រោះយោបល់ដោយបើកចំហ និងពិតប្រាកដ លើសេចក្តីព្រាងច្បាប់នេះ និងសេចក្តីព្រាងច្បាប់ទាំងអស់ ដែលមានសារៈសំខាន់ជាស្នូល ដើម្បីសម្រេចបាននូវសិទ្ធិមនុស្ស។

**វ៉ាន់-ហ៊ីលី** (Wan-Hea Lee)
តំណាង
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

**រ៉ាណា ហ្វ្ល័វើរស៍** (Rana Flowers)
តំណាង
មូលនិធិអង្គការសហប្រជាជាតិ ដើម្បីកុមារ (UNICEF)

**ម៉ារឃ៍ ឌឺវីអ៊ីវ** (Marc Derveeuw)
តំណាង
មូលនិធិអង្គការសហប្រជាជាតិ សម្រាប់ប្រជាជន (UNFPA)

**វ៉េននី គូស៊ូម៉ា** (Wenny Kusuma)
តំណាង
ទីភ្នាក់ងារអង្គការសហប្រជាជាតិទទួលបន្ទុកសមភាពយ៉េនឌ័រ និងការផ្តល់អំណាចឲ្យស្ត្រី (UN Women)